# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

**Kampuchea Action to Promote Education (KAPE)**

## សេចក្តីជូនដំណឹងស្តីពី

### ការអញ្ជើញចូលរួមដេញថ្លៃការជួសជុលអគារសិក្សា និងផ្គត់ផ្គង់គ្រឿងសង្ហារិម សម្រាប់គម្រោង សាលារៀនជំនាន់ថ្មី នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ក្រោមជំនួយថវិកាដោយក្រសួងអប់រំ យុវជន និងកីឡា

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុនសំណង់ និងអ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ក្នុងស្រុកទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គម្រោង សាលារៀនជំនាន់ថ្មី នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងដាក់ឱ្យចូលរួមដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដើម្បីជួសជុលអគារសិក្សា និងផ្គត់ផ្គង់គ្រឿងសង្ហារិមនៅ **អនុវិទ្យាល័យ អញ្ញរង្សី ខេត្ត សៀមរាប និង វិទ្យាល័យ ព្រះអង្គឌួង ខេត្ត ព្រៃវែង ក្នុងឆ្នាំ២០២៥ នេះ។**

ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសាងសង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ដែលមានម្ចាស់តែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុនសំណង់ ឬអ្នកម៉ៅការសាងសង់ ឬសហគ្រាស សិប្បកម្ម ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយ ឬម្ចាស់តែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសាងសង់ និងសហគ្រាស សិប្បកម្ម ដែលមានចំណាប់អារម្មណ៍ សូមធ្វើការទាក់ទងមកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីសាកសួរព័ត៌មានអំពីការចូលរួមដេញថ្លៃ និងការរៀបចំឯកសារភ្ជាប់ក្នុងការបញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ រហូតដល់ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ៥:០០ល្ងាច ជាកំហិត តាមរយៈសារអេឡិចត្រូនិច (មានជូនភ្ជាប់អសយដ្ឋានអ៊ីមែល) ព្រមទាំងចម្លងជូន (CC) អ្នកពាក់ព័ន្ធទាំងអស់។

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) និងធ្វើការកោះអញ្ជើញប្រជុំតម្រង់ទិសស្តីអំពីនីតិវិធីនៃការបំពេញឯកសារសម្រង់តម្លៃសម្រាប់ស្នើសុំចូលរួមដេញថ្លៃតាមរយៈអនឡាញ (Zoom Meet) នឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ០៩:៣០នាទីព្រឹក។

<u>បញ្ជាក់</u>៖

- ក្រោយពីការប្រជុំតម្រង់ទិសរួច ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ ត្រូវរៀបចំឯកសារដេញថ្លៃដែលបានបំពេញរួច ប្រគល់ជូនផ្នែករដ្ឋបាល ការិយាល័យរង (សាលារៀនជំនាន់ថ្មី) អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ស្ថិតនៅក្នុងបរិវេណ វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ។
- ការប្រជុំបើកកញ្ចប់ឯកសារដេញថ្លៃនឹងប្រព្រឹត្តិទៅដោយផ្ទាល់នៅសាលប្រជុំរបស់វិទ្យាល័យព្រះស៊ីសុវត្ថិរាជធានីភ្នំពេញ (សាលារៀនជំនាន់ថ្មី) ចំណែកកាលបរិច្ឆេទនៃការបើកកញ្ចប់ឯកសារដេញថ្លៃសូមជូនដំណឹងពេលក្រោយ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ នឹងត្រូវចែកជូនតែក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដែលបានមកចូលរួមប្រជុំតម្រង់ទិសតែប៉ុណ្ណោះ។
- អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងមិនទទួលខុសត្រូវក្នុងការបើកកញ្ចប់ដេញថ្លៃទេ ប្រសិនគ្រប់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ណាមួយដែលអវត្តមានមិនបានអញ្ជើញមកចូលរួមស្តាប់ការណែនាំ និងការតម្រង់ទិសជំនួយស្មារតីនៃការចូលរួមដេញថ្លៃ មានដូចជា៖ (គំរូប្លង់ រូបភាព ទីតាំងសាលារៀន និងផ្សេងទៀត)។

- រាល់ឯកសារសម្រង់តម្លៃ (ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម១០%) ប្រសិនបើមានការបញ្ចុះតម្លៃ ត្រូវបញ្ចុះឱ្យរួចជាស្រេចមុនការបើកកញ្ចប់ដេញថ្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ត្រូវច្រកក្នុងស្រោមបិទផ្សិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យរង (សាលារៀនជំនាន់ថ្មី) ផ្នែករដ្ឋបាល នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ស្ថិតនៅក្នុងបរិវេណ វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ ហើយហាមដាច់ខាតមិនអនុញ្ញាតឱ្យដាក់ផ្ញើមកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល តេឡេក្រាម WhatsApp........) ឡើយ។
- គ្រប់ក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ទាំងអស់ អាចចូលរួមដេញថ្លៃបានលុះត្រាតែក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម នោះបានចុះទៅសិក្សាមើលទីតាំងសាលារៀនគោលដៅដោយផ្ទាល់ និងប្រៀបធៀបជាមួយ BoQ ដែលបានផ្តល់ដោយគម្រោង ហើយមានការចុះហត្ថលេខា បោះត្រាទទួលស្គាល់ពីនាយកសាលារៀនគោលដៅថាពិតជាបានចុះពិនិត្យមើលត្រឹមត្រូវពិតប្រាកដមែន (ការចុះពិនិត្យការងារត្រូវធ្វើមិនមែនចុះទៅបោះត្រានាយកសាលារៀនទេ) និងដាក់នៅក្នុងស្រោមសំបុត្រដោយឡែកពីពាក្យសុំចូលរួមដេញថ្លៃដើម្បីងាយស្រួលគណៈកម្មការលទ្ធកម្មត្រួតពិនិត្យមុននឹងបើកកញ្ចប់ដេញថ្លៃ។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ដែលមិនបានដាក់ជូនមកផ្នែករដ្ឋបាល ការិយាល័យរង (សាលារៀនជំនាន់ថ្មី) របស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាមោឃៈ។
- អ្នកបានដាក់ពាក្យដេញថ្លៃទាំងអស់ ត្រូវតែអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យបានទាន់ពេលវេលាកំណត់ ប្រសិនបើករណីអ្នកដេញថ្លៃណាមួយដែលមិនបានមកចូលរួមប្រជុំបើកកញ្ចប់ដេញថ្លៃតាមពេលវេលាកំណត់ទេ ឬក៏អវត្តមានក្នុង (រយៈពេល១៥នាទី) ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុនសំណង់ ម្ចាស់អ្នកម៉ៅការសំណង់ និងម្ចាស់សហគ្រាស សិប្បកម្ម ។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទនៃការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើមានករណីចាំបាច់ ហើយយើងខ្ញុំនឹងធ្វើសេចក្តីជូនដំណឹងជាមុនទៅក្រុមហ៊ុនសំណង់ អ្នកម៉ៅការសំណង់ និងសហគ្រាស សិប្បកម្ម ដែលបានផ្ញើឯកសារដេញថ្លៃទៅតាមអសយដ្ឋាននៅក្នុងបញ្ជីចុងក្រោយ។
- រាល់ឯកសារដែលដាក់មកហើយ គណៈកម្មការយើងខ្ញុំនឹងមិនប្រគល់ជូនត្រឡប់ទៅវិញឡើយ។

ព័ត៌មានផ្សេងៗសូមទំនាក់ទំនង៖


ការិយាល័យរង៖ អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (សាលារៀនជំនាន់ថ្មី)

អាស័យដ្ឋាន ៖ ស្ថិតនៅក្នុងបរិវេណ វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ

ឈ្មោះ ៖ ឈួន សារ៉ាន ជាប្រធានរដ្ឋបាល និងធនធានមនុស្ស

ទូរស័ព្ទ ៖ ០១២ ៧៥២ ៥៥៣, ០៩៦ ៤៦៤ ៧៧៧៧, ០៩៧ ៦៩៨ ៨៤៨៤

អ៊ីមែល ៖ saran@kapekh.org

ចម្លងជូន ៖ vanna@kapekh.org, huon@kapekh.org, sambath@kapekh.org, run@kapekh.org sinak.pha@kapekh.org, soria@kapekh.org, ladet@kapekh.org,


ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
កំពង់ចាម, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥

នាយកប្រតិបត្តិ

KAMPUCHEA ACTION TO PROMOTE EDUCATION.ORG

សៅ វណ្ណា